របាយការណ៍ត្រួតពិនិត្យការវាយតម្លៃលទ្ធភាពសង

លេខ: ០០៥/២៦

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦

# ស៊ីអាយអេ ហ្វីសត៍ អ៊ីនធើណេសិនណាល ស្គូល

| ចំណាត់ថ្នាក់ឥណទាន | | ព័ត៌មានសញ្ញាបណ្ណទី ១ | | ព័ត៌មានសញ្ញាបណ្ណទី ២ | |
|---|---|---|---|---|---|
| ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន | **khBB** | ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ | **khAAA** | ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ | **khAAA** |
| ទស្សនវិស័យ | ស្ថិរភាព | ទំហំ | ១០ លានដុល្លារអាមេរិក | ទំហំ | ១០ លានដុល្លារអាមេរិក |
| ប្រវត្តិនៃការវាយតម្លៃលទ្ធភាពសង | | កាលបរិច្ឆេទបោះផ្សាយ | ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ | កាលបរិច្ឆេទបោះផ្សាយ | ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៥ |
| ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន | **khBB** | កាលបរិច្ឆេទឥណប្រតិទាន | ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៨ | កាលបរិច្ឆេទឥណប្រតិទាន | ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០៣០ |
| ទស្សនវិស័យ | **អវិជ្ជមាន** | ប្រភេទ | មិនមានទ្រព្យតម្កល់ មានបុគ្គលធានា | ប្រភេទ | មិនមានទ្រព្យតម្កល់ មានបុគ្គលធានា |
| ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ | **khAAA** | អត្រាគូប៉ុង | ៦,៣% ក្នុងមួយឆ្នាំ | អត្រាគូប៉ុង | ៥,៦% ក្នុងមួយឆ្នាំ |
| កាលបរិច្ឆេទបោះផ្សាយ | ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥ | បុគ្គលធានា | **Credit Guarantee & Investment Facility (CGIF)** | បុគ្គលធានា | **Credit Guarantee & Investment Facility (CGIF)** |


## អ្នកវាយតម្លៃ៖

លោក ស៊ីសុវត្តិ ចក្រការា CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

លោក ជូ ដេវីត
z.david@ratingagencyofcambodia.com.kh
(+៨៥៥) ៨៦ ៨៦៦ ១៩៨

លោក ពឹង ធៀមហេង
p.theamheng@ratingagencyofcambodia.com.kh
(+៨៥៥) ៨៩ ៦២១ ៨៣៣


## ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

យើងរក្សាចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន និងចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ របស់ស៊ីអាយអេ ហ្វីសត៍ អ៊ីនធើណេសិនណាល ស្គូល («CIA» ឬ «ក្រុមហ៊ុន») នៅ «**khBB**» និង «**khAAA**» ប៉ុន្តែយើងបានផ្លាស់ប្តូរទស្សនវិស័យពី «**អវិជ្ជមាន**» មកជា «**ស្ថិរភាព**» ។

ប្រតិបត្តិការរបស់ CIA នៅតែរក្សាបាននូវស្ថិរភាពក្នុងឆ្នាំហិរញ្ញវត្ថុ ២០២៥ ដែលជំរុញដោយកំណើនចំណូលជាបន្តបន្ទាប់។ កំណើននេះគឺដោយសារការកើនឡើងនៃចំនួនសិស្សចុះឈ្មោះចូលរៀន និង ការបង្កើនតម្លៃសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើប្រៀបនឹងឆ្នាំចាស់ (ឆ្នាំ២០២៤) អាត្រាកំណើននៃប្រាក់ចំណូលមានការថយចុះ ដោយសារ CIA មានអាត្រាប្រើប្រាស់ខ្ពស់រហូតដល់ ៨៨,០%។ ក្នុងពេលជាមួយគ្នានេះ ប្រាក់ចំណេញប្រតិបត្តិការបានកើនឡើង ៤,៥% រីឯប្រាក់ចំណេញសុទ្ធបានកើនឡើងយ៉ាងខ្លាំងរហូតដល់ ២០,៤%។ សម្រាប់ពេលខាងមុខ ផែនការពង្រីកសាខារបស់ CIA អាចនឹងជួយជំរុញកំណើនចំណូលឱ្យកាន់តែខ្ពស់ ប៉ុន្តែសមាមាត្របំណុលខ្ពស់អាចនឹងដាក់សម្ពាធលើប្រាក់ចំណេញ។

តាមទស្សនៈរបស់យើង លទ្ធផលប្រតិបត្តិការបច្ចុប្បន្ន ផែនការយុទ្ធសាស្ត្រសម្រាប់សាខាទីបួន និងគណៈគ្រប់គ្រងដែលមានបទពិសោធន៍របស់ CIA បានបង្កើតឱ្យមានជំហរយ៉ាងរឹងមាំក្នុងការទាញយកអត្ថប្រយោជន៍ពីឱកាសនានាដែលកើតចេញពីការកើនឡើងនៃប្រជាជនចំណូលមធ្យមនៅក្នុងប្រទេស។ កត្តានេះត្រូវបានរំពឹងថានឹងជួយជំរុញកំណើនចំណូលឱ្យមានស្ថិរភាព ដែលអនុញ្ញាតឱ្យ CIA រក្សាបាននូវសមត្ថភាពប្រកួតប្រជែងនៅក្នុងទីផ្សារកម្រិតមធ្យមនេះ។


©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.



អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh


RAC website

## ទស្សនវិស័យ

យើងរំពឹងថា CIA នឹងរក្សាកំណើនចំណូលក្នុងឆ្នាំហិរញ្ញវត្ថុ ២០២៦ ជាមួយនឹងការបើកដំណើរការដំណាក់កាលទីពីរនៃសាខាទីបួន នាខែសីហា ឆ្នាំ២០២៦។ គិតត្រឹមដំណាច់ឆ្នាំ ២០២៥ ដំណាក់កាលទីមួយនៃសាខាទីបួនបានដំណើរការពេញលេញ ដោយមានសិស្សចំនួន ៣៦០នាក់ ក្នុងឆ្នាំសិក្សាដំបូង ខណៈដែលដំណាក់កាលទីពីរសម្រេចបាន ៧៥% តាមផែនការដែលបានរំពឹងទុក។ ទោះជាយ៉ាងណាក៏ដោយ យើងរំពឹងថានឹងមានការកើនឡើងនូវចំណាយប្រតិបត្តិការ ចំណាយការប្រាក់ និងបំណុល ដោយសារផែនការពង្រីកសាខា ដែលអាចដាក់សម្ពាធលើប្រាក់ចំណេញ ប៉ុន្តែយើងរំពឹងថាបញ្ហានេះនឹងត្រូវបានកាត់បន្ថយតាមរយៈការកើនឡើងនៃលទ្ធផលប្រតិបត្តិការ និង លំហូរសាច់ប្រាក់ពីប្រតិបត្តិការពីការពង្រីកសាខាដោយជោគជ័យ។ បន្ថែមពីនេះ ការមិនបែងចែកភាគលាភក្នុងឆ្នាំហិរញ្ញវត្ថុ ២០២៦ នឹងជួយសម្រាលសម្ពាធលើសន្ទនីយភាពរបស់ CIA និងពង្រឹងភាពបត់បែនផ្នែកហិរញ្ញវត្ថុ។ ហេតុដូច្នេះ យើងសម្រេចផ្លាស់ប្តូរទស្សនវិស័យមក «**ស្ថិរភាព**»។

## កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ក្នុងករណីបង្កើនចំណាត់ថ្នាក់លុះត្រាតែ កំណើនប្រាក់ចំណេញប្រកបដោយចីរភាព ឥទ្ធិពលវិជ្ជមានខ្លាំងក្លាពីប្រតិបត្តិការនៃសាខាទីបួន និងផែនការពង្រីកសាខាថ្មីៗនាពេលអនាគត ព្រមទាំងការប្រសើរឡើងនៃសន្ទនីយភាព នឹងនាំឱ្យយើងពិនិត្យមើលការវាយតម្លៃរបស់យើង។ ក្នុងករណីបន្ទាបចំណាត់ថ្នាក់ នៅពេលទម្រង់ហានិភ័យហិរញ្ញវត្ថុកាន់តែអាក្រក់អាចឱ្យមានការផ្លាស់ប្តូរការវាយតម្លៃ។ លើសពីនេះទៅទៀត ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ ត្រូវបានភ្ជាប់ទៅក្នុងចំណាត់ថ្នាក់សកលរបស់ CGIF (AA ដោយ S&P Global Ratings) ។ ដូច្នេះ យើងអាចពិចារណាលើការបន្ទាបចំណាត់ថ្នាក់ ឥណទានសញ្ញាបណ្ណ ប្រសិនបើការវាយតម្លៃជាសកលរបស់ CGIF ត្រូវបានបន្ទាបចំណាត់ថ្នាក់នោះ។

## បញ្ហាដែលត្រូវត្រួតពិនិត្យ

សមាមាត្រនៃបំណុល ផែនការបែងចែកភាគលាភ វឌ្ឍនភាពនៃដំណាក់កាលទីពីរនៃសាខាទីបួន និងផែនការពង្រីកសាខាថ្មីៗនាពេលអនាគត ដែលអាចធ្វើឱ្យកើនឡើងនូវចំណាយប្រតិបត្តិការនិងចំណាយការប្រាក់ ព្រមទាំងចំនួនសិស្សចុះឈ្មោះចូលរៀន និងអាត្រានៃការប្រើប្រាស់ នឹងត្រូវត្រួតពិនិត្យយ៉ាងជិតដល់។

# សេចក្តីសង្ខេបអំពី ស៊ីអាយអេ ហ្វឹសត៍ អ៊ីនធើណេសិនណល ស្គូល

## ទិដ្ឋភាពទូទៅ

ក្នុងឆ្នាំ២០២៥ CIA សម្រេចបាននូវចំណូលខ្ពស់បំផុត ដែលជំរុញដោយកំណើនចំនួនសិស្សចុះឈ្មោះចូលរៀន ៥,៥% និងការកើនឡើងនៃកម្រិតថ្លៃសិក្សា ៨,០% ធៀបនឹងឆ្នាំមុន។ ការព្យាករណ៍សេដ្ឋកិច្ចមានភាពវិជ្ជមានសម្រាប់ប្រទេសកម្ពុជាដោយ ADB និង IMF រួមជាមួយនឹងការបន្តកើនឡើងនៃការចុះឈ្មោះសិស្សនៅក្នុងសាលាឯកជនក្នុងរាជធានីភ្នំពេញ ក្នុងរយៈពេលបួនឆ្នាំចុងក្រោយ (២០២២ ដល់ ២០២៥) បង្ហាញពីឱកាសរីកចម្រើនបន្ថែមសម្រាប់ CIA។ ប៉ុន្តែ ក្រុមហ៊ុនកំពុងប្រឈមមុខនឹងបញ្ហាមួយចំនួន រួមទាំងការកើនឡើងនៃការចំណាយប្រតិបត្តិការដែលលើសពីកំណើនប្រាក់ចំណូល និងការកើនឡើងនៃការចំណាយហិរញ្ញវត្ថុ ដែលជះឥទ្ធិពលដល់ពិន្ទុឥណទាន នាំឲ្យចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនរក្សានៅ «**khBB**» ។

## ការប្រត្តិបត្តិ

ក្នុងឆ្នាំហិរញ្ញវត្ថុ ២០២៥ ចំណូលរបស់ CIA សម្រេចបាន ៣១,៧ លានដុល្លារអាមេរិក ដែលកើនឡើង ១២,០% ធៀបនឹងឆ្នាំមុន ដោយសារកំណើនថ្លៃសិក្សា និងការចុះឈ្មោះចូលរៀន។ ចំណាយប្រតិបត្តិការបានកើនឡើង ១៥,០% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីការកើនឡើងនៃចំណាយលើបុគ្គលិក និងថ្លៃរំលស់។ ទោះបីជាមានការកើនឡើងនូវចំណាយប្រតិបត្តិការក៏ដោយ ក៏ CIA នៅតែអាចរក្សាបាននូវអនុបាតប្រាក់ចំណេញប្រតិបត្តិការក្នុងកម្រិត ២១,៦%។ បន្ថែមពីនេះ ប្រាក់ចំណេញសុទ្ធរបស់ CIA បានកើនឡើងយ៉ាងខ្លាំងរហូតដល់ ២០,៤% ធៀបនឹងឆ្នាំមុន ដោយសម្រេចបានអនុបាតប្រាក់ចំណេញសុទ្ធ ១៨,៧% តាមរយៈការធ្លាក់ចុះនៃចំណាយហិរញ្ញវត្ថុចំនួន ៤៣,៩% ធៀបនឹងឆ្នាំមុន។ ទោះជាយ៉ាងណាក៏ដោយ ការហក់ឡើងនៃចំណាយប្រតិបត្តិការ និងបំណុល បានធ្វើឱ្យលទ្ធផលហិរញ្ញវត្ថុរបស់ CIA ក្នុងឆ្នាំ ២០២៥ មានភាពចុះខ្សោយ ដែលបានឱ្យឃើញតាមរយៈការថយចុះនៃចំនួនថ្ងៃមធ្យមនៃសាច់ប្រាក់ក្នុងដៃ និងសូចនាករបំណុលមានសភាពកាន់តែអាក្រក់។ យ៉ាងណាមិញ ការថយចុះនៃចំណាយហិរញ្ញវត្ថុបានជួយអនុបាតលទ្ធភាពសងឱ្យប្រសើរឡើងវិញ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

និយមន័យចំណាត់ថ្នាក់ឥណទាន

| ចំណាត់ថ្នាក់វាយតម្លៃឥណទាន(ចំណាត់ថ្នាក់ជាតិ) | | | |
|---|---|---|---|
| ចំណាត់ថ្នាក់ជាតិ | និយមន័យ | | |
| khAAA | សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ១ | ហានិភ័យទាបណាស់ |
| khAA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ២ | |
| khA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៣ | ហានិភ័យទាប |
| khBBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុង កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៤ | |
| khBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៥ | ហានិភ័យមធ្យម |
| khB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៦ | |
| khCCC | សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល | ៧ | ហានិភ័យខ្ពស់ |
| khCC | សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៨ | |
| khC | ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៩ | ហានិភ័យខ្ពស់ណាស់ |
| khD | មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់ | ១០ | |

កំណត់សម្គាល់៖
ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្ទៀងផ្ទាត់ដោយឯករាជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះ បង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website